**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**Ministry of Agriculture Forestry and Fisheries**
**គម្រោងពិពិធកម្មកសិកម្មកម្ពុជា**
**Cambodia Agricultural Sector Diversification Project**
**World Bank Loan No .IDA Credit 6366-KH**

**អង្គភាពសម្របសម្រួលគម្រោង**
លេខ: ...០៧៥.....CASDP/MAFF

ថ្ងៃសុក្រ ៧កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២១

## ជម្រាបជូន
## លោកប្រធានភ្នាក់ងារអនុវត្តគម្រោងថ្នាក់ខេត្តពាក់ព័ន្ធ
## នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា

**កម្មវត្ថុ** ៖ ស្តីពីការផ្សព្វផ្សាយបន្តនូវសេចក្តីជូនដំណឹងស្តីពីការផ្តល់ហិរញ្ញប្បទានបន្ថែមទុនវិនិយោគ។

**យោង** ៖ លិខិតលេខ០០៤ CASDP/MAFF ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២១ របស់អង្គភាពសម្របសម្រួលគម្រោងពិពិធកម្មកសិកម្មកម្ពុជា។

**ជូនភ្ជាប់** ៖- សេចក្តីជូនដំណឹង ស្តីពីការបន្តទទួលសំណើសុំជំនួយហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ (Matching Grant Facility) សម្រាប់តំបន់១.................................ចំនួន១ច្បាប់

- សេចក្តីជូនដំណឹង ស្តីពីការបន្តទទួលសំណើសុំជំនួយហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ (Matching Grant Facility) សម្រាប់តំបន់២.................................ចំនួន ១ច្បាប់
- សេចក្តីជូនដំណឹង ស្តីពីការទទួលសំណើសុំជំនួយហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ (Matching Grant Facility) សម្រាប់តំបន់៣.................................ចំនួន ១ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ យោង និងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាប លោកប្រធាន ជ្រាបថា គម្រោងពិពិធកម្មកសិកម្មកម្ពុជាបានធ្វើសេចក្តីជូនដំណឹងបន្ថែមដល់អ្នកពាក់ព័ន្ធនៅក្នុងបណ្តាឃុំ និងស្រុកនៃខេត្តនីមួយៗឲ្យបានទូលំទូលាយអំពីការជ្រើសរើសសហគមន៍កសិកម្ម ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យមដែលកំពុងប្រតិបត្តិការអាជីវកម្មពាក់ព័ន្ធវិស័យកសិកម្ម ក្នុងការទទួលសំណើសុំជំនួយហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ (Matching Grant Facility-MGF) ដូចមានជូនភ្ជាប់មកជាមួយ។

អាស្រ័យហេតុនេះ សូម លោកប្រធាន ជ្រាប និងជួយផ្សព្វផ្សាយបន្ត តាមការគួរ។

សូម លោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**អគ្គលេខាធិការរង**
**និងជានាយកគម្រោង**

ឈរ ជីត្រា

**ចម្លងជូន៖**
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពាក់ព័ន្ធ
"ដើម្បីជ្រាប"
-ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ (ជាន់ផ្ទាល់ដី នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ)
ទូរស័ព្ទទំនាក់ទំនង: +៨៥៥-១១ ៨៩៦ ០១១/ +៨៥៥-៩២ ២០៣ ៣០៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបន្តទទួលសំណើសុំជំនួយហិរញ្ញប្បទានឥតសំណង បំពេញបន្ថែមទុនវិនិយោគ ( Matching Grant Facility )

គម្រោងពិពិធកម្មកសិកម្មកម្ពុជា (Cambodia Agricultural Sector Diversification Project) សូមជូនដំណឹងដល់សាធារណជនទាំងអស់ មេត្តាជ្រាបថា កន្លងមកនេះ អង្គភាពសម្របសម្រួលគម្រោងបានធ្វើការជូនដំណឹងដល់ក្រុមផលិត សហគមន៍កសិកម្ម និងកសិ-ធុរកិច្ចខ្នាតតូចនិងមធ្យម (អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម អ្នកប្រមូលទិញ អ្នកកែច្នៃ) ក្នុងខេត្តគោលដៅរបស់គម្រោង រួមមាន ខេត្តបាត់ដំបង និងសៀមរាប ដែលមានចំណាប់អារម្មណ៍ដាក់ពាក្យស្នើសុំជំនួយហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ ដោយធ្វើការទំនាក់ទំនងផ្ទាល់មកក្រុមការងារផ្តល់សេវាគាំទ្របច្ចេកទេសនៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដើម្បីបំពេញទម្រង់សំណើពិពិធកម្មកសិកម្ម និងសំណើធុរកិច្ច រួចផ្តល់ជូន អង្គភាពសម្របសម្រួលគម្រោងចាប់ពីថ្ងៃទី៧ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២១។ ដោយសារស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩ ជាលក្ខណៈសហគមន៍ និងក្នុងន័យផ្តល់ពេលវេលានិងឱកាសដល់សហគមន៍កសិកម្ម ក្រុមផលិត និងកសិ-ធុរកិច្ចខ្នាតតូចនិងមធ្យម ដើម្បីទទួលបាននូវហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគនេះ អង្គភាពសម្របសម្រួលគម្រោង សូមជូនដំណឹងថានឹងបន្តទទួលសំណើសុំចាប់ពីថ្ងៃទី៨ ខែមីនា រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ដោយស្នើសហគមន៍កសិកម្ម ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូចនិងមធ្យម បំពេញទម្រង់សំណើសុំខាងលើ ស្របតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម ៖

- ម្ចាស់សំណើត្រូវស្ថិតនៅក្នុងតំបន់ប្រតិបត្តិការរបស់គម្រោងពិពិធកម្មកសិកម្មកម្ពុជា
- ម្ចាស់សំណើត្រូវមានសកម្មភាពធុរកិច្ចរបស់ខ្លួន ដែលទាក់ទងនឹងផលិតកម្មកសិកម្ម និងការកែច្នៃ ក្នុងកម្រិតបឋម ពាក់កណ្តាលសម្រេច និងសម្រេច
- ម្ចាស់សំណើត្រូវមានការទទួលស្គាល់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ម្ចាស់សំណើត្រូវមានចំណាប់អារម្មណ៍ពិតប្រាកដក្នុងការចូលរួមអនុវត្តសកម្មភាពធុរកិច្ចនៅក្នុងខ្សែច្រវាក់តម្លៃផលិតកម្មកសិកម្ម ក្រៅពីផលិតកម្មស្រូវ
- ម្ចាស់សំណើដែលកំពុងប្រតិបត្តិការនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ផលិតផលកសិកម្ម ក្រៅពីផលិតផលស្រូវ ឬមានចំណាប់អារម្មណ៍យ៉ាងជាក់លាក់ក្នុងការចូលរួមនៅក្នុងខ្សែច្រវាក់តម្លៃផលិតកម្មកសិកម្ម ដែលមិនផ្តោតលើដំណាំស្រូវ ថ្នាំជក់ និងគ្រឿងស្រវឹង ក្នុងខេត្តគោលដៅរបស់គម្រោង
- ម្ចាស់សំណើដែលជាសហគ្រាសខ្នាតតូចនិងមធ្យម ត្រូវតែជាសហគ្រាសឯកជន ១០០% និងមាននិយោជិកមិនលើសពី ១០០នាក់ ព្រមទាំងមានទ្រព្យសម្បត្តិហិរញ្ញវត្ថុ (មិនរាប់បញ្ចូលដី) ក្រោម ៥០០.០០០ ដុល្លារ
- ម្ចាស់សំណើត្រូវតែជាអាជីវករដែលអាជីវកម្មរបស់ខ្លួនត្រូវបានចុះបញ្ជី ឬបើជាសមាគមផលិតកម្មគឺត្រូវបានបង្កើតឡើងស្របតាមច្បាប់ ដោយមានការបង់ពន្ធគិតរហូតដល់ពេលបច្ចុប្បន្ន ឬត្រូវបានលើកលែងពីការបង់ពន្ធស្របតាមច្បាប់។ ក្រុមផលិត និងសហគ្រាសខ្នាតតូចនិងមធ្យម ដែលទើបតែបានបង្កើតឡើងស្របតាមច្បាប់កាលពីពេលថ្មីៗនេះ ក៏មានសិទ្ធិចូលរួមផងដែរ
- ម្ចាស់សំណើត្រូវយល់ព្រមអនុវត្តទៅតាមលក្ខខណ្ឌផ្សេងៗទៀត ដែលតម្រូវដោយគម្រោង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រុមផលិត សហគមន៍កសិកម្ម កសិ-ធុរកិច្ចខ្នាតតូចនិងមធ្យម (អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម អ្នកប្រមូលទិញ អ្នកកែច្នៃ) ក្នុងខេត្តគោលដៅរបស់គម្រោង ដូចជាខេត្តបាត់ដំបង និងសៀមរាប ដែលមានចំណាប់អារម្មណ៍ សូមធ្វើការទំនាក់ទំនងផ្ទាល់មកក្រុមការងារផ្តល់សេវាគាំទ្របច្ចេកទេសនៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដើម្បីបំពេញទម្រង់សំណើសុំខាងលើជាភាសាខ្មែរ រួចដាក់ក្នុងស្រោមសំបុត្របិទជិត ចំនួន៣ច្បាប់ និងចម្លងឌីជីថល (USB memory stick in write-protected pdf-format) និងផ្ញើមកកាន់អង្គភាពសម្របសម្រួលគម្រោងនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្ទប់ជាន់ផ្ទាល់ដីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដែលមានអាសយដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

**ក. ក្រុមការងារគម្រោងពិពិធកម្មកសិកម្មកម្ពុជាទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- លោកបណ្ឌិត **សរ ចិត្រា** នាយកគម្រោង លេខទូរស័ព្ទ ០៧៧ ៥៦៣ ៣៧៧
- លោក **ហុក គឹមឆួន** ប្រធានគ្រប់គ្រងគម្រោង លេខទូរស័ព្ទ ០១៦ ៤៤៩ ៦៩៣

អ៊ីម៉ែល: casdp@maff.gov.kh

គេហទំព័រ: https://casdp.maff.gov.kh

**ខ. ក្រុមការងារផ្តល់សេវាគាំទ្របច្ចេកទេស** (Technical Service Provider) ដើម្បីទទួលបាននូវទម្រង់សំណើសុំ។

តំបន់១៖ ខេត្តបាត់ដំបង និងសៀមរាប

លោក ជឿង ស៊ីសូរិន ប្រធានទីប្រឹក្សាបច្ចេកទេស លេខទូរសព្ទ: ០៩២ ៨០០ ៨០១

**សូមអរគុណ**!!!

THE WORLD BANK

# សេចក្តីជូនដំណឹង
# ស្តីពី
# ការបន្តទទួលសំណើសុំជំនួយហិរញ្ញប្បទានឥតសំណង បំពេញបន្ថែមទុនវិនិយោគ (Matching Grant Facility)

គម្រោងពិពិធកម្មកសិកម្មកម្ពុជា (Cambodia Agricultural Sector Diversification Project) សូមជូនដំណឹងដល់សាធារណជនទាំងអស់ មេត្តាជ្រាបថា កន្លងមកនេះ អង្គភាពសម្របសម្រួលគម្រោងបានធ្វើការជូនដំណឹងដល់ក្រុមផលិត សហគមន៍កសិកម្ម និងកសិ-ធុរកិច្ចខ្នាតតូចនិងមធ្យម (អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម អ្នកប្រមូលទិញ អ្នកកែច្នៃ) ក្នុងខេត្តគោលដៅរបស់គម្រោង រួមមាន ខេត្តព្រះវិហារ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ និងខេត្តត្បូងឃ្មុំ ដែលមានចំណាប់អារម្មណ៍ដាក់ពាក្យស្នើសុំជំនួយហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ ដោយធ្វើការទំនាក់ទំនងផ្ទាល់មកក្រុមការងារផ្តល់សេវាគាំទ្របច្ចេកទេសនៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដើម្បីបំពេញទម្រង់សំណើពិពិធកម្មកសិកម្ម និងសំណើធុរកិច្ច រួចផ្តល់ជូនអង្គភាពសម្របសម្រួលគម្រោងចាប់ពីថ្ងៃទី៧ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២១។ ដោយសារស្ថានភាពវិករាលដាលនៃជំងឺកូវីដ-១៩ ជាលក្ខណៈសហគមន៍ និងក្នុងន័យផ្តល់ពេលវេលានិងឱកាសដល់សហគមន៍កសិកម្ម ក្រុមផលិត និងកសិ-ធុរកិច្ចខ្នាតតូចនិងមធ្យម ដើម្បីទទួលបាននូវហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគនេះ អង្គភាពសម្របសម្រួលគម្រោង សូមជូនដំណឹងថា នឹងបន្តទទួលសំណើសុំ ចាប់ពីថ្ងៃទី៨ ខែមីនា រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ដោយស្នើសហគមន៍កសិកម្ម ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូចនិងមធ្យម បំពេញទម្រង់សំណើសុំខាងលើ ស្របតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម ៖

- ម្ចាស់សំណើត្រូវស្ថិតនៅក្នុងតំបន់ប្រតិបត្តិការរបស់គម្រោងពិពិធកម្មកសិកម្មកម្ពុជា
- ម្ចាស់សំណើត្រូវមានសកម្មភាពធុរកិច្ចរបស់ខ្លួន ដែលទាក់ទងនឹងផលិតកម្មកសិកម្ម និងការកែច្នៃ ក្នុងកម្រិតបឋម ពាក់កណ្តាលសម្រេច និងសម្រេច
- ម្ចាស់សំណើត្រូវមានការទទួលស្គាល់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ម្ចាស់សំណើត្រូវមានចំណាប់អារម្មណ៍ពិតប្រាកដក្នុងការចូលរួមអនុវត្តសកម្មភាពធុរកិច្ចនៅក្នុងខ្សែច្រវាក់តម្លៃផលិតកម្មកសិកម្ម ក្រៅពីផលិតកម្មស្រូវ
- ម្ចាស់សំណើដែលកំពុងប្រតិបត្តិការនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ផលិតផលកសិកម្ម ក្រៅពីផលិតផលស្រូវ ឬមានចំណាប់អារម្មណ៍យ៉ាងជាក់លាក់ក្នុងការចូលរួមនៅក្នុងខ្សែច្រវាក់តម្លៃផលិតកម្មកសិកម្ម ដែលមិនផ្តោតលើដំណាំស្រូវ ថ្នាំជក់ និងគ្រឿងស្រវឹង ក្នុងខេត្តគោលដៅរបស់គម្រោង
- ម្ចាស់សំណើដែលជាសហគ្រាសខ្នាតតូចនិងមធ្យម ត្រូវតែជាសហគ្រាសឯកជន ១០០% និងមាននិយោជិកមិនលើសពី ១០០នាក់ ព្រមទាំងមានទ្រព្យសម្បត្តិហិរញ្ញវត្ថុ (មិនរាប់បញ្ចូលដី) ក្រោម ៥០០.០០០ ដុល្លារ
- ម្ចាស់សំណើត្រូវតែជាអាជីវករដែលអាជីវកម្មរបស់ខ្លួនត្រូវបានចុះបញ្ជី ឬបើជាសមាគមផលិតកម្មគឺត្រូវបានបង្កើតឡើងស្របតាមច្បាប់ ដោយមានការបង់ពន្ធគិតរហូតដល់ពេលបច្ចុប្បន្ន ឬត្រូវបានលើកលែងពីការបង់ពន្ធស្របតាមច្បាប់។ ក្រុមផលិត និងសហគ្រាសខ្នាតតូចនិងមធ្យម ដែលទើបតែបានបង្កើតឡើងស្របតាមច្បាប់កាលពីពេលថ្មីៗនេះ ក៏មានសិទ្ធិចូលរួមផងដែរ
- ម្ចាស់សំណើត្រូវយល់ព្រមអនុវត្តទៅតាមលក្ខខណ្ឌផ្សេងៗទៀត ដែលតម្រូវដោយគម្រោង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រុមផលិត សហគមន៍កសិកម្ម កសិ-ធុរកិច្ចខ្នាតតូចនិងមធ្យម (អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម អ្នកប្រមូលទិញ អ្នកកែច្នៃ) ក្នុងខេត្តគោលដៅរបស់គម្រោង ដូចជាខេត្តព្រះវិហារ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ និងខេត្តត្បូងឃ្មុំដែលមានចំណាប់អារម្មណ៍ សូមធ្វើការទំនាក់ទំនងផ្ទាល់មកក្រុមការងារផ្តល់សេវាគាំទ្របច្ចេកទេសនៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដើម្បីបំពេញទម្រង់សំណើសុំខាងលើជាភាសាខ្មែរ រួចដាក់ក្នុងស្រោមសំបុត្របិទជិត ចំនួន៣ច្បាប់ និងចម្លងឌីជីថល (USB memory stick in write-protected pdf-format) និងផ្ញើមកកាន់អង្គភាពសម្របសម្រួលគម្រោងនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្ទប់ជាន់ផ្ទាល់ដីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដែលមានអាសយដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖**

**ក. ក្រុមការងារគម្រោងពិពិធកម្មកសិកម្មកម្ពុជានៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- លោកបណ្ឌិត **សរ ចិត្រា** នាយកគម្រោង លេខទូរស័ព្ទ ០៧៧ ៥៦៣ ៣៧៧
- លោក **ហុក គឹមធួន** ប្រធានគ្រប់គ្រងគម្រោង លេខទូរស័ព្ទ ០១៦ ៤៤៩ ៦៩៣

អ៊ីម៉ែល: casdp@maff.gov.kh

គេហទំព័រ: https://casdp.maff.gov.kh

**ខ. ក្រុមការងារផ្តល់សេវាគាំទ្របច្ចេកទេស** (Technical Service Provider) ដើម្បីទទួលបាននូវទម្រង់សំណើសុំ

តំបន់២ ៖ ខេត្តព្រះវិហារ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ និងខេត្តត្បូងឃ្មុំ

លោក លាង សម្បត្តិ ប្រធានទីប្រឹក្សាបច្ចេកទេស លេខទូរសព្ទ៍: -០១២ ៧៩៧ ៣៧៣

-០៩៧ ៤៦៣ ៣៦១៣

**សូមអរគុណ!!!**

# សេចក្តីជូនដំណឹង
# ស្តីពី
# ការទទួលសំណើសុំជំនួយហិរញ្ញប្បទានឥតសំណង
# បំពេញបន្ថែមទុនវិនិយោគ( Matching Grant Facility )

គម្រោងពិពិធកម្មកសិកម្មកម្ពុជា (Cambodia Agricultural Sector Diversification Project) ដែលត្រូវបាននិងកំពុងអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹកនិងឧតុនិយម ក្រោមហិរញ្ញប្បទានពីធនាគារពិភពលោក (World Bank) និងរាជរដ្ឋាភិបាលកម្ពុជា សូមជូនដំណឹងដល់សាធារណជនទាំងអស់មេត្តាជ្រាបថា គម្រោងនឹងធ្វើការផ្តល់ជំនួយហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ (Matching Grant Facility-MGF) ដល់សហគមន៍កសិកម្ម ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូចនិងមធ្យម ដែលកំពុងប្រតិបត្តិការអាជីវកម្មពាក់ព័ន្ធវិស័យកសិកម្ម នៅទូទាំងខេត្តកំពង់ចាម កំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង រាជធានីភ្នំពេញ។ ដើម្បីទទួលបាននូវជំនួយហិរញ្ញប្បទានឥតសំណងខាងលើ សហគមន៍កសិកម្ម ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូចនិងមធ្យម ត្រូវដាក់សំណើពិពិធកម្មកសិកម្ម និងសំណើធុរកិច្ច ស្របតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម ៖

- ម្ចាស់សំណើត្រូវស្ថិតនៅក្នុងតំបន់ប្រតិបត្តិការរបស់គម្រោងពិពិធកម្មកសិកម្មកម្ពុជា
- ម្ចាស់សំណើត្រូវមានសកម្មភាពធុរកិច្ចរបស់ខ្លួន ដែលទាក់ទងនឹងផលិតកម្មកសិកម្ម និងការកែច្នៃ ក្នុងកម្រិតបឋម ពាក់កណ្តាលសម្រេច និងសម្រេច
- ម្ចាស់សំណើត្រូវមានការទទួលស្គាល់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ម្ចាស់សំណើត្រូវមានចំណាប់អារម្មណ៍ពិតប្រាកដក្នុងការចូលរួមអនុវត្តសកម្មភាពធុរកិច្ចនៅក្នុងខ្សែច្រវាក់តម្លៃផលិតកម្មកសិកម្មក្រៅពីផលិតកម្មស្រូវ
- ម្ចាស់សំណើដែលកំពុងប្រតិបត្តិការនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ផលិតផលកសិកម្ម ក្រៅពីផលិតផលស្រូវ ឬមានចំណាប់អារម្មណ៍យ៉ាងជាក់លាក់ក្នុងការចូលរួមនៅក្នុងខ្សែច្រវាក់តម្លៃផលិតកម្មកសិកម្ម ដែលមិនផ្តោតលើដំណាំស្រូវ ថ្នាំជក់ និងគ្រឿងស្រវឹង ក្នុងខេត្តគោលដៅរបស់គម្រោង
- ម្ចាស់សំណើដែលជាសហគ្រាសខ្នាតតូចនិងមធ្យម ត្រូវតែជាសហគ្រាសឯកជន ១០០% និងមាននិយោជិកមិនលើសពី ១០០នាក់ ព្រមទាំងមានទ្រព្យសម្បត្តិហិរញ្ញវត្ថុ (មិនរាប់បញ្ចូលដី) ក្រោម ៥០០.០០០ ដុល្លារ
- ម្ចាស់សំណើត្រូវតែជាអាជីវករដែលអាជីវកម្មរបស់ខ្លួនត្រូវបានចុះបញ្ជី ឬបើជាសមាគមផលិតកម្មគឺត្រូវបានបង្កើតឡើងស្របតាមច្បាប់ ដោយមានការបង់ពន្ធគិតរហូតដល់ពេលបច្ចុប្បន្ន ឬត្រូវបានលើកលែងពីការបង់ពន្ធស្របតាមច្បាប់។ ក្រុមផលិត និងសហគ្រាសខ្នាតតូចនិងមធ្យម ដែលទើបតែបានបង្កើតឡើងស្របតាមច្បាប់កាលពីពេលថ្មីៗនេះ ក៏មានសិទ្ធិចូលរួមផងដែរ
- ម្ចាស់សំណើត្រូវយល់ព្រមអនុវត្តទៅតាមលក្ខខណ្ឌផ្សេងៗទៀត ដែលតម្រូវដោយគម្រោង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រុមផលិត សហគមន៍កសិកម្ម កសិ-ធុរកិច្ចខ្នាតតូចនិងមធ្យម (អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម អ្នកប្រមូលទិញ អ្នកកែច្នៃ) ក្នុងខេត្តគោលដៅរបស់គម្រោងរួមមាន ខេត្តកំពង់ចាម កំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង រាជធានីភ្នំពេញដែលមានចំណាប់អារម្មណ៍ សូមធ្វើការទំនាក់ទំនងផ្ទាល់មកក្រុមការងារផ្តល់សេវាគាំទ្របច្ចេកទេសនៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដើម្បីបំពេញទម្រង់សំណើសុំខាងលើជាភាសាខ្មែរ រួចដាក់ក្នុងស្រោមសំបុត្របិទជិត ចំនួន៣ច្បាប់ និងចម្លងឌីជីថល (USB memory stick in write-protected pdf-format) និងផ្ញើមកកាន់អង្គភាពសម្របសម្រួលគម្រោងនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្ទប់ជាន់ផ្ទាល់ដីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដែលមានអាសយដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង០៨:០០នាទីព្រឹក ដល់ម៉ោង១៧:០០នាទីល្ងាច។

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖**

**ក. ក្រុមការងារគម្រោងពិពិធកម្មកសិកម្មកម្ពុជានៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- លោកបណ្ឌិត **សរ ចិត្រា** នាយកគម្រោង លេខទូរស័ព្ទ ០៧៧ ៥៦៣ ៣៧៧
- លោក **ហុក គឹមធួន** ប្រធានគ្រប់គ្រងគម្រោង លេខទូរស័ព្ទ ០១៦ ៤៤៩ ៦៩៣

អ៊ីម៉ែល: casdp@maff.gov.kh

គេហទំព័រ: https://casdp.maff.gov.kh

**ខ. ក្រុមការងារផ្តល់សេវាគាំទ្របច្ចេកទេស** (Technical Service Provider) ដើម្បីទទួលបាននូវទម្រង់សំណើសុំ

តំបន់៣ ៖ ខេត្តកំពង់ចាម កំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង រាជធានីភ្នំពេញ

-លោក **អ៊ុង សឿង** ប្រធានទីប្រឹក្សាបច្ចេកទេស លេខទូរសព្ទ័: ០១២ ៩១០ ៣៩១

-លោក **សន ធី** ទីប្រឹក្សាកសិកម្ម និងអ្នកផលិត លេខទូរសព្ទ័: ០១២ ៤៤២ ០១៦

**សូមអរគុណ**!!!